ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ១០៧ ក.ប/ស.ជ.ណ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រារព្ធទិវាពិភពលោក ដើម្បីសុខភាព និងសុវត្ថិភាពការងារ
# ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់គ្រប់ មន្ទីរការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត និយោជក សហព័ន្ធសហជីព ព្រមទាំងកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថានទាំងអស់ឲ្យបានជ្រាបថា **ទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ** ត្រូវបានរៀបចំឡើង នៅថ្ងៃទី ២៨ ខែ មេសា ជារៀងរាល់ឆ្នាំដោយប្រទេសជាសមាជិក នៃអង្គការអន្តរជាតិខាងការងារ ក្នុង គោលបំណង ដើម្បីលើកកម្ពស់សុខភាព និងសុវត្ថិភាពការងារ និងរំលឹកដល់វិញ្ញាណខ័ន្ធកម្មករនិយោជិត ដែលបានបាត់បង់ជីវិតដោយ សារគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈនៅលើពិភពលោក។ នេះជាឆ្នាំទី ១១ ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រារព្ធទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ ក្រោមប្រធានបទ " **ភាពតានតឹងអារម្មណ៍នៅកន្លែងធ្វើការជាបញ្ហាប្រឈមរួម** "។

ដើម្បីរួមចំណែកក្នុងការផ្សព្វផ្សាយ និងលើកកម្ពស់សុខភាព និងសុវត្ថិភាពការងារ និងបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈជាយថាហេតុដល់បងប្អូន កម្មករនិយោជិត សូមលោក លោកស្រីប្រធាន ឬ ម្ចាស់សហគ្រាសគ្រឹះស្ថានទាំងអស់ ដែលបានបោះទីតាំងនៅតាមបណ្តារាជធានី-ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំប្រារព្ធទិវានេះឲ្យបានអធិកអធមនៅតាមសហគ្រាស គ្រឹះស្ថានរបស់ខ្លួន និងចងបដាពាក្យស្លោកមួយចំនួននៅតាមរបងខាងមុខសហគ្រាស គ្រឹះស្ថាន ដើម្បីចូលរួមអបអរសាទរទិវាពិភពលោក ដើម្បីសុខភាព និងសុវត្ថិភាពការងារ មានដូចខាងក្រោម៖

១. អបអរសាទរទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារ
២. រួមគ្នាកសាងវប្បធម៌ នៃការបង្ការសុខភាព និងសុវត្ថិភាពការងារ
៣. ធានាឲ្យគ្រប់កន្លែងការងារមានសុវត្ថិភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា
៤. និយោជក និងកម្មករនិយោជិតធ្វើការរួមគ្នាដើម្បីធានាឲ្យកន្លែងការងារប្រកបដោយសុខភាព និង សុវត្ថិភាពការងារល្អ
៥. បង្ការ និងទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍ និងលុបបំបាត់ការរើសអើងនៅកន្លែងការងារ
៦. កន្លែងការងារប្រកបដោយសុខភាព និងសុវត្ថិភាពល្អ នាំឲ្យកើនផលិតភាព និងប្រាក់ចំណូល
៧. និយោជកត្រូវផ្តល់សម្ភារៈការពារបុគ្គលដល់កម្មករនិយោជិត

៨. រួមគ្នាកាត់បន្ថយគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ
៩. ជីវិតរបស់ខ្ញុំ ការងាររបស់ខ្ញុំ និងការងារប្រកបដោយសុវត្ថិភាពរបស់ខ្ញុំ
១០.ការងារសមរម្យ គឺជាការងារប្រកបដោយសុវត្ថិភាព
១១. រួមគ្នាការពារហានិភ័យដែលកើតឡើងដោយភាពតានតឹងអារម្មណ៍នៅកន្លែងធ្វើការ
១២. ភាពតានតឹងអារម្មណ៍បណ្តាលឱ្យផលិតភាពថយចុះ
១៣. បរិយាកាសការងារល្អគ្មានភាពតានតឹងអារម្មណ៍
១៤. ភាពតានតឹងអារម្មណ៍នៅកន្លែងធ្វើការជាក្តីកង្វល់របស់យើងទាំងអស់គ្នា
១៥. គ្រឿងញៀនបំផ្លាញសុខភាព និងអនាគត របស់យើង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា មន្ទីរការងារ និង បណ្តុះ-បណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត សមាគមនិយោជក និងនិយោជក ព្រមទាំងសហភាពសហព័ន្ធសហជីព និងសហព័ន្ធសហជីព នៃសហគ្រាស គ្រឹះស្ថានទាំងអស់នឹងអនុវត្តតាមសេចក្តីជូន ដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព កម្មករនិយោជិត
  "ដើម្បីជូនជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ